សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៤៨ ខែមករា-កុម្ភៈ ឆ្នាំ២០១០
Issue: 48 January-February 2010

# ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

## សង្គមស៊ីវិលទទូចសុំឱ្យកិច្ចប្រជុំពេញអង្គលើកទី៧ គិតគូរយកចិត្ត ទុកដាក់នូវសិទ្ធិរបស់ជនរងគ្រោះ

## Civil Society Urges the 7th ECCC Plenary to Consider Victims' Rights with Care

កាលពីថ្ងៃទី២ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅនេះ កិច្ចប្រជុំពេញអង្គលើកទី ៧ នៃ ចៅក្រម នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រព្រឹត្តទៅក្រោមអធិបតីភាព លោកចៅក្រម **គង់ ស្រ៊ីម** និង លោកស្រីចៅក្រម **ស៊ីលវ៉ា ខាតរ៉ាយ** ដើម្បីធ្វើការពិភាក្សា និងអនុម័តវិធានផ្ទៃក្នុងដែលត្រូវធ្វើការកែសម្រួលជាពិសេស គឺពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។



ECCC *ចៅក្រម គង់ ស្រ៊ីម និង ស៊ីលវ៉ា ខាតរ៉ាយ*

លោកចៅក្រម **គង់ ស្រ៊ីម** ដែលជាប្រធានអង្គប្រជុំ និង ជាប្រធានតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញ បានថ្លែងបើកអង្គប្រជុំដោយគូសបញ្ជាក់នូវការវិវត្តន៍រីកចំរើនជាច្រើនដែលអង្គជំនុំជម្រះសម្រេចបាន ចាប់ពេលចាប់ផ្តើមរហូតមកទល់ពេលបច្ចុប្បន្ននេះ ពិសេស ទាក់ទិននឹងការបើកសវនាការទៅលើសំណុំរឿង ០០១ ដែលមានជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** និងបានបញ្ចប់ទៅប្រកបដោយភាពជោគជ័យ ព្រមទាំងការបិទបញ្ចប់ការស៊ើបអង្កេតទៅលើសំណុំ រឿង០០២ កាលពីអំឡុងឆ្នាំ២០០៩ កន្លងទៅនេះដែរ ។ លោកចៅក្រម ក៏បានលើកឡើងគូសបញ្ជាក់បន្ថែមថា គោលបំណងនៃកិច្ចប្រជុំពេញអង្គចៅក្រមលើកនេះ ដើម្បីអនុម័តទៅលើសំណើវិសោធនកម្មវិធានផ្ទៃក្នុងដែលជាច្បាប់តុលាការពិសេសនេះពាក់ព័ន្ធជុំវិញការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី ដើម្បីធ្វើយ៉ាងណាឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព សម្រាប់ដំណើរការប្រព្រឹត្តទៅនៃសំណុំរឿង០០២ ដែលមានលក្ខណៈស្មុគស្មាញ និងមានជនរងគ្រោះ ចូលរួមដាក់ពាក្យចូលរួមជាច្រើន។ តាមរយៈទិន្នន័យរបស់អង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញ បានទទួល រហូតមកត្រឹមដំណាច់ខែមករា ឆ្នាំ២០១០នេះ គឺមានពាក្យបណ្តឹង សរុបប្រមាណ ៨,១៩០ ដែលក្នុងនោះ មានពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤,០០៤។

ចំណែកឯ លោកស្រី **ស៊ីលវ៉ា ខាតរ៉ាយ** ជាចៅក្រមអន្តរជាតិ នៃ អង្គជំនុំជម្រះសាលាដំបូង និងជាអនុប្រធាននៃកិច្ចប្រជុំពេញអង្គនេះ ក៏បានគូសបញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានទទួលស្គាល់នូវការចូលរួមរបស់ជនរងគ្រោះទៅក្នុងការកាត់ក្តី ព្រោះវាជារឿងដ៏សំខាន់មួយ ហេតុដូចនេះ បានជាគេត្រូវការឱ្យសវនាការប្រព្រឹត្តទៅដោយរលូន និងដោះស្រាយប្រកបដោយប្រសិទ្ធភាព និងទាន់វេលាចំពោះពាក្យបណ្តឹងរបស់ជនរងគ្រោះ។

ទន្ទឹមពេលដែលកិច្ចប្រជុំពេញអង្គលើកនេះ ប្រព្រឹត្តទៅក្នុងគោលបំណង ដើម្បីធ្វើឱ្យមានប្រសើរឡើងនូវប្រសិទ្ធភាពសម្រាប់ជំរុញ ភាពជឿនលឿនទៅមុខនៃសំណុំរឿង០០២ ដែរ អង្គការសង្គមស៊ីវិល ក៏បានសំដែងនូវក្តីព្រួយបារម្ភ និងស្នើអនុសាសន៍មួយចំនួនទាក់ទិន និងការធ្វើការវិសោធនកម្មវិធានផ្ទៃក្នុងនោះដែរ។ ជាក់ស្តែង គឺគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធនៃអង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ២១ ដែលបានតាមដានយ៉ាងជិតដិតនូវដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ បានចេញសេចក្តីថ្លែងការណ៍មួយ កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០១០ កន្លងទៅនេះ។

សេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិល បានលើកឡើងនូវចំណុចព្រួយបារម្ភនិងអនុសាសន៍មួយចំនួនដូចខាងក្រោម:

ទី១- គឺថា គណៈកម្មាធិការប្រព្រឹត្តិកម្ម កត់សំគាល់ឃើញថា វាមានចំណុចវិវត្តន៍វិជ្ជមានជាច្រើន។ ជាពិសេស សង្គម

អាសយដ្ឋាន : ផ្ទះលេខ៩Eo ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន។ ទូរស័ព្ទ/ទូរសារ: (០២៣ ) ៣០១ ៤១៥ អ៊ីមែល: chrac@forum.org.kh គេហទំព័រ: www.chrac.org

ស៊ីវិលអបអរសាទរចំពោះ**ការពង្រីកនូវអាណត្តិរបស់អង្គភាពជនរងគ្រោះ** ដើម្បីឱ្យអាចបង្កើត និងអនុវត្តន៏នូវកម្មវិធីផ្សេងៗ និងវិធានមិនមែនផ្លូវច្បាប់ ដទៃទៀត ដើម្បីឆ្លើយតបទៅនឹងផលប្រយោជន៏របស់ជនរងគ្រោះ ឱ្យបានកាន់តែទូលំទូលាយជាងមុនថែមទៀត។ ការណ៏នេះ នឹងត្រូវការឱ្យមានយុទ្ធសាស្ត្របែបពិភាក្សានិងសហប្រតិបត្តិការមួយ នៅក្នុងការរៀបចំនូវវិធានការទាំងនេះ ព្រមជាមួយនឹងការរៀបចំនានាសម្រាប់បែបបទរដ្ឋបាល និងថវិកា ដើម្បីធានាឱ្យមានការអនុវត្តន៏ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត យើងក៏ឃើញមានការស្នើឡើងនូវកំណើនដែលធ្លាប់ត្រូវបានទាមទារឱ្យមានអស់រយៈពេលដ៏យូរនៃក៏វិតថវិកា ដែលផ្តល់ដោយតុលាការទៅលើការតំណាងតាមផ្លូវច្បាប់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ នៅក្នុងន័យនេះ សង្គមស៊ីវិល ក៏បានទទូចសុំដល់តុលាការ និងម្ចាស់ជំនួយនានាឱ្យផ្តល់នូវធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការតំណាងតាមផ្លូវច្បាប់នូវផលប្រយោជន៏របស់ដើមបណ្តឹងរដ្ឋប្បវេណីប្រកបដោយភាពឆ្លាតវៃ និងសមស្របនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីច្បាប់។

ទី២- បញ្ហា**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី** ដែលនឹងតំណាងឱ្យក្រុមរួមបញ្ចូលគ្នាតែមួយ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ទោះបីជា ភាពលំអិតជាច្រើននៃក្របខ័ណ្ឌសហមេធាវីនាំមុខនៅពេលអនាគត នឹងត្រូវថែងបន្ថែមក៏ដោយ ប៉ុន្តែនៅពេលនេះ សង្គមស៊ីវិលបានអំពាវនាវដល់ចៅក្រមកុំឱ្យក៏វិតនូវតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងតែមានហួសពីអ្វីដែលចាំបាច់ដើម្បីធានាឱ្យមានប្រសិទ្ធភាពនៃសវនាការនិងគោរពទៅលើសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឧ. ដូចជា សិទ្ធិក្នុងការជ្រើសរើសមេធាវី របស់គេផងដែរ។ ចំពោះបញ្ហានេះ បទប្បបញ្ញត្តិជាច្រើនត្រូវការចាំបាច់ឱ្យមាន ដើម្បីធានាមាននូវយន្តការបែបសហប្រតិបត្តិការគ្នា រវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីសំរាប់ជាផលប្រយោជន៏របស់កូនក្តីនៃ មេធាវីទាំងនោះ ក៏ដូចជា ពហុភាព នៃទស្សនៈរបស់ជនរងគ្រោះដែលនឹងត្រូវតំណាងនៅក្នុងតុលាការផងដែរ។

ទី៣-គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏សំដែងក្តីបារម្ភជាខ្លាំងចំពោះការក៏វិត ដែលបានស្នើឡើងសំរាប់**ការទាមទារសំណងមកត្រឹម ជាការទាមទារតែមួយ និងដាក់បញ្ចូលគ្នា** ដែលនឹងមានតែការផ្តល់សំណងតែមួយ។ សម្ព័ន្ធអង្គការនេះយល់ថា បទប្បញ្ញត្តិនេះ ហាក់ដូចជាប្រមាថមើលងាយដល់ចរិតលក្ខណៈ និងទំហំនៃភាពឈឺចាប់ របស់ជនរងគ្រោះ ពីព្រោះ ដោយបានបដិសេធនូវឱកាសរបស់ពួកគេ ក្នុងការបញ្ចេញនូវពហុភាពនៃភាពឈឺចាប់របស់គេ ទៅតាមរយៈមធ្យោបាយដែលមានន័យចំពោះគេ និងដែលរារាំងដល់ចៅក្រមមិនឱ្យសម្រេចបាននូវលទ្ធផលដ៏ត្រឹមត្រូវ និងយុត្តិធម៌សំរាប់ជនរងគ្រោះ ផងដែរ។ នៅខណៈពេលដែលចៅក្រមយល់ឃើញថា វាជាការសមស្របក្នុងការក៏វិតនូវការចេញសំណង ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពនោះ វាដូចជាមិនសមស្របទេក្នុងការក៏វិតមិនឱ្យជនរងគ្រោះបញ្ចេញនូវភាពឈឺចាប់រងគ្រោះ ដែលបានទទួលរង និង រារាំងគេមិនឱ្យបញ្ចេញសំលេងលើកឡើងអំពីសំណងជូនដល់តុលាការនោះ។

ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមទទូចស្នើសុំដល់ អង្គជំនុំជម្រះវិសាមញ្ញ ដូចខាងក្រោមៈ

១- ធានាថា កម្មវិធីនានាសំរាប់ជនរងគ្រោះ និងវិធានការមិនមែនតាមផ្លូវច្បាប់ដទៃទៀត ត្រូវបានរៀបចំឡើងតាមបែបចូលរួម ហើយថា បទប្បញ្ញត្តិអំពីបែបរដ្ឋបាលចាំបាច់ និងរចនាសម្ព័ន្ធថវិកាត្រូវតែមាន ដើម្បីជួយឱ្យមានការអនុវត្តន៏ប្រកបដោយប្រសិទ្ធភាព។

២- ធានាថាក្របខ័ណ្ឌជំនួយផ្នែកច្បាប់ដែលមានលក្ខណៈត្រឹមត្រូវ សំរាប់ដើមបណ្តឹងរដ្ឋប្បវេណីមានធនធានគ្រប់គ្រាន់ ដើម្បីអាចឱ្យមានភាពតំណាងតាមផ្លូវច្បាប់ដ៏សមរម្យនូវផលប្រយោជន៏សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់តំណាក់កាលទាំងអស់ នៃដំណើរការនីតិវិធីច្បាប់។

៣- ធានាថាតួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានក៏វិតឱ្យហួសពីអ្វីដែលចាំបាច់ ក្នុងការធានាឱ្យមានប្រសិទ្ធភាពនៃសវនាការ ដោយត្រូវណែនាំឱ្យមានបទប្បញ្ញត្តិ គ្រប់គ្រាន់សំរាប់ធានាឱ្យមានយុទ្ធសាស្ត្របែបសហប្រតិបត្តិការគ្នា រវាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដោយត្រូវយកចិត្តទុកដាក់ទៅលើសិទ្ធិជាមូលដ្ឋាន និងផលប្រយោជន៏របស់ដើមបណ្តឹងរដ្ឋប្បវេណី។

៤- ពន្យារការធ្វើវិសោធនកម្មទៅលើវិធានមួយចំនួន ដែលទាក់ទិននឹងសំណងទៅកិច្ចប្រជុំពេញអង្គលើកក្រោយទៀត ដើម្បីទុកពេលវេលាឱ្យចៅក្រមធ្វើការពិចារណាឱ្យបានពេញលេញ នូវគោលនយោបាយអំពីសំណង និងការអនុវត្តន៏សំណងតាមរបៀបមួយដែលវៃឆ្លាត និង ដោយមានការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត ផងដែរ។

ដូចនេះ ជាមួយនឹងសេចក្តីថ្លែងការណ៏នេះ សង្គមស៊ីវិល

យល់ថាចំណុចទាំងនេះ នឹងជួយជាការពិចារណាបន្ថែមទៀត សម្រាប់កិច្ចប្រជុំ ពេញអង្គក្នុងការគិតគូរនូវតួនាទី និងសារៈសំខាន់របស់ជនរងគ្រោះ ឱ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការស្វែងរកយុត្តិធម៌របស់ខ្លួន។

# បញ្ចប់កិច្ចស៊ើបសួរសំរាប់សំណុំរឿង ០០២

## Closing Investigation for Case 002



*លោកចៅក្រម* ***យូ ប៊ុនឡេង*** *និង លោក* ***ម៉ាក់សែល ឡឺម៉ុងដ៍***

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ កន្លងទៅ ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីប្រកាសព័ត៌មានជាផ្លូវការអំពី ការប្រកាសបិទការស៊ើបអង្កេតទៅលើសំណុំរឿង០០២ ដែលមានជនត្រូវចោទចំនួន ៤រូប គឺលោក **នួន ជា** (អតីតប្រធានសភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យ), លោក **ខៀវ សំផន** (អតីតប្រមុខរដ្ឋ), លោក **អៀង សារី** (អតីតឧបនាយករដ្ឋមន្ត្រី- រដ្ឋមន្ត្រីក្រសួងការបរទេស), លោកស្រី **អៀង ធីរិទ្ធ** (អតីតរដ្ឋមន្ត្រីសង្គមកិច្ច)។ នៅក្នុងការប្រកាសបិទសំណុំរឿង០០២នេះ សហចៅក្រមស៊ើបអង្កេត ក៏បានដាក់បញ្ចូលឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** (អតីតប្រធានមន្ទីរស-២១ ឬគុកទួលស្លែង) ផងដែរ ទោះបីជាជនជាប់ចោទរូបនេះ ធ្លាប់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជំនុំជម្រះ និងបានបញ្ចប់ទៅ កាលពីខែវិច្ឆិកា ឆ្នាំ២០០៩ រួចហើយ ហើយកំពុងរង់ចាំការប្រកាសសាលក្រម ក៏ដោយ។

នៅសេចក្តីប្រកាសព័ត៌មាននោះ សហចៅក្រមស៊ើបអង្កេតដែលមានលោកចៅក្រម **យូ ប៊ុនឡេង** (សហចៅក្រមស៊ើបអង្កេតជាតិ) និងលោក **ម៉ាក់សែល ឡឺម៉ុងដ៍** (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ) បានពន្យល់ថា ការិយាល័យរបស់លោកបានធ្វើការស៊ើបអង្កេតសំណុំរឿងនេះ រយៈពេលជាង២ឆ្នាំកន្លះមកហើយ បន្ទាប់ពីបានទទួលដីកាបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីការិយាល័យសហព្រះរាជអាជ្ញា ដែលបានដាក់ជូនតាំងពីខែកក្កដា ឆ្នាំ២០០៧ កន្លងទៅនេះ។ ការស៊ើបអង្កេតនេះ ធ្វើឡើងទៅលើឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តទៅនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដោយមានឯកសារជាច្រើនម៉ឺនទំព័រ ចំលើយសាក្សី ពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងផងដែរ។

សហចៅក្រមស៊ើបអង្កេត បានពន្យល់ទៀតថា កិច្ចស៊ើបអង្កេតបានធ្វើឡើងតែនៅក្នុងវិសាលភាព នៃកិច្ចស៊ើបអង្កេតប៉ុណ្ណោះ ដែលនេះមានន័យថា គឺធ្វើឡើងតែចំពោះទីតាំងឧក្រិដ្ឋកម្ម និងប្រភេទឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញតែប៉ុណ្ណោះ។ ដូចនេះ ប្រសិនបើភាគីណាមួយនៅក្នុងរឿងក្តីនេះមិនអស់ចិត្តចំពោះការបិទការស៊ើបអង្កេតនេះ គឺមានរយៈពេលតែ ៣០ថ្ងៃទៀតប៉ុណ្ណោះ ក្នុងការស្នើសុំការស៊ើបសួរបន្ថែម ចាប់ពីថ្ងៃដែលសហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងនេះ។

ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេត ក៏បានប្រកាសឱ្យដឹងថា ខ្លួននឹងអាចចេញដីកាដំណោះស្រាយសំរាប់បញ្ជូនរឿងឱ្យទៅជំនុំជម្រះ ប្រហែលជានៅខែកញ្ញា ឆ្នាំ២០១០ ខាងមុខនេះ ប្រសិនបើ គ្មានឧបសគ្គអ្វីកើតឡើងចំពោះដំណើរការនីតិវិធីច្បាប់ទេនោះ។ ដូចនេះ ជាមួយនឹងការប្រកាសនេះ គេសង្ឃឹមថា សវនាការកាត់សេចក្តីទៅលើសំណុំរឿង ០០២ នឹងអាចប្រព្រឹត្តឡើងបាន នៅបន្ទាប់ពីការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលនឹងគូសបញ្ជាក់ឱ្យកាន់តែច្បាស់ផងដែរនូវជនត្រូវចោទ, ប្រភេទបទល្មើសចោទប្រកាន់អំពើឧក្រិដ្ឋកម្មនានាប្រឆាំងនឹងជនត្រូវចោទទាំងនោះ ភស្តុតាងនានា (រួមទាំងសាក្សី) និង ចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់ជាផ្លូវការ។

នៅខណៈពេលស្របគ្នានេះ ដើម្បីជាការសម្របសម្រួល និងធានាឱ្យប្រសិទ្ធភាពការងារ អង្គភាពជនរងគ្រោះ នៃ អង្គជំនុំជម្រះវិសាមញ្ញក៏បានចេញសេចក្តីជូនដំណឹងនៅថ្ងៃ១៤ ខែមករា ឆ្នាំ២០១០ នោះដែរអំពីកាលបរិច្ឆេទបញ្ចប់ការទទួលនូវពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ ដែលត្រូវនឹងដែនកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត **នៅត្រឹមថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ វេលាម៉ោង ៧:០០ ល្ងាច**។ រយៈពេលកំណត់នេះ គឺធ្វើឡើងដោយអនុឡោមទៅតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ដែលកំណត់ឱ្យមានរយៈពេល១៥ថ្ងៃ បន្ទាប់ពីថ្ងៃប្រកាស បិទការស៊ើបអង្កេតសំណុំរឿង០០២ នេះ។ ម្យ៉ាងវិញទៀត ជនរងគ្រោះដទៃទៀត ដែលចង់ចូលរួមនៅក្នុងសំណុំរឿង ០០២ នេះ ក៏អាចដាក់ជា**ពាក្យបណ្តឹងធម្មតាជូនទៅកាន់ការិយាល័យសហព្រះរាជអាជ្ញា មកត្រឹមថ្ងៃ ទី ៨ ខែកុម្ភៈ ឆ្នាំ២០១០ នេះ តាមរយៈអង្គភាពជនរងគ្រោះ** ដោយយោងទៅតាមការប្រកាសជូនដំណឹងបន្ថែមទៀត ពីខាងការិយាល័យសហព្រះរាជអាជ្ញា។

# អង្គបុរេជំនុំជម្រះបន្តបើកសវនាការបណ្តឹងឧទ្ធរណ៍ជាលើកទីពីរ៣

## Pre-Trial Chamber Hears 3rd Pre-Trial Detention Appeals


អៀង សារី


ខៀវ សំផន


អៀង ធីរិទ្ធ

អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការជំនុំជម្រះទៅលើករណីបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ជនត្រូវចោទ **អៀង សារី**, **ខៀវ សំផន** និង **អៀង ធីរិទ្ធ** ដែលត្រូវបានប្រព្រឹត្តឡើងជាបន្តបន្ទាប់ នៅថ្ងៃទី ១១, ១២ និង ១៥ ខែកុម្ភៈ ឆ្នាំ២០១០ នេះ។

បណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំបណ្តោះអាសន្ន របស់ជនត្រូវចោទទាំងបីរូបនេះ គឺធ្វើឡើងជាលើកទី ៣ ហើយ បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញ បានចេញដីកាបដិសេធការសុំនៅក្រៅឃុំ កាលពីពេលមុនៗ។ ការសុំនៅក្រៅឃុំបណ្តោះអាសន្នជាលើកទី៣ នេះ ក៏ដោយសារតែសហចៅក្រមស៊ើបអង្កេត ដែលមានលោក **យូ ប៊ុនឡេង និង លោក ម៉ាសែល ឡឺម៉ុង** បានចេញដីកាបន្តថេរវេលាឃុំខ្លួនបណ្តោះអាសន្នរយៈពេល១ ឆ្នាំទៀត សម្រាប់ជនត្រូវចោទម្នាក់ៗ ដែលរយៈពេលនេះ យ៉ាងយូរបំផុតត្រឹមខែកញ្ញា ឆ្នាំ២០១០ ខាងមុខនេះ។

យោងទៅតាមវិធានផ្ទៃក្នុង របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកំណត់ថា ជនត្រូវចោទ (តាមរយៈមេធាវីការពារ) អាចធ្វើបណ្តឹងឧទ្ធរណ៍សុំនៅក្រៅឃុំបណ្តោះអាសន្នបាន ដោយប្តឹងទៅអង្គបុរេជំនុំជម្រះ។ យោងទៅតាមច្បាប់នេះ សហចៅក្រមស៊ើបអង្កេតអាចចេញដីកាឃុំខ្លួនបណ្តោះអាសន្នទៅលើ ជនត្រូវចោទ បានសម្រាប់រយៈពេល១ឆ្នាំ ម្តង ហើយអាចបន្តរហូតដល់បីដង ចំពោះប្រភេទបទចោទប្រកាន់មកលើជនត្រូវចោទទាំងបី តួយ៉ាងដូចជា បទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ម្យ៉ាងទៀត បើយោងតាម**វិធាន៦៣** នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏បានកំណត់នូវលក្ខខណ្ឌសំខាន់ៗមួយចំនួន ដែលអាចអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ទៅលើជនត្រូវចោទបាន ដូចជា:

១- មានមូលហេតុដែលត្រូវបានគេរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

២- សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បី:

- រារាំងកុំឱ្យជនត្រូវចោទនោះគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការ របស់អង្គជំនុំជម្រះវិសាមញ្ញ។
- ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។
- ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី
- ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ
- រក្សាសណ្តាប់ធ្នាប់សាធារណៈ។

ដូចនេះ នៅក្នុងសវនាការនៃអង្គបុរេជំនុំជម្រះ ភាគីជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ **អៀង សារី**, **ខៀវ សំផន** និង **អៀង ធីរិទ្ធ** ត្រូវតែលើកបង្ហាញភស្តុតាងសំអាងជូនអង្គចៅក្រមថា ប្រសិនបើត្រូវដោះលែងនោះ ជនត្រូវចោទនឹងមិនរំលោភបំពានទៅលើលក្ខខណ្ឌណាមួយនៃលក្ខខណ្ឌទាំងអស់នោះទេ។

ទោះបីជាសវនាការបណ្តឹងឧទ្ធរណ៍ បានចប់សព្វគ្រប់ហើយក៏ដោយ ក៏ប៉ុន្តែការប្រកាសសាលដីកាសំរេចដោះលែងបណ្តោះអាសន្ន ឬដាក់ឃុំខ្លួនបន្តទៅលើជនត្រូវចោទទាំងបីនាក់នេះ នៅមិនទាន់ប្រកាសឱ្យដឹងភ្លាមៗបន្ទាប់ពីសវនាការនោះទេ។

### ព័ត៌មានសំខាន់:

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ ហើយចង់សាកសួរព័ត៌មានអំពីសាលាក្តីខ្មែរ ក្រហមបន្ថែមទៀត

**សូមទាក់ទង:**

- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១
- ការិយាល័យកិច្ចការសាធារណៈ: លេខទូរស័ព្ទ: ០១២ ៤៨៨ ១៥៦

➢ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញ តាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ www.krtrial.info

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី (DED) ទេ។*

**ឧបត្ថម្ភមូលនិធិដោយ: ឌី.អ៊ី.ឌី**

ded Deutscher Entwicklungsdienst